ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ : ០១៩ ប្រក ......ប.ស្ក

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការត្រួតពិនិត្យ និងការធ្វើអធិការកិច្ចការបំពុលបរិស្ថាន

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក
- បានឃើញអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង
- បានឃើញអនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូហ្សូន



អគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០

- បានឃើញអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ដីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងបង្កើនប្រសិទ្ធភាពការត្រួតពិនិត្យ និងការធ្វើអធិការកិច្ចការបំពុលបរិស្ថានប្រកបដោយតម្លាភាព និងគណនេយ្យភាពក្នុងការអនុវត្តការកិច្ចស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន សំដៅធានាកិច្ចគាំពារបរិស្ថាននិងសុខភាពសាធារណៈ។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅ ដូចតទៅ៖

- កំណត់ក្របខ័ណ្ឌសមត្ថកិច្ចអនុវត្តការត្រួតពិនិត្យ និងការធ្វើអធិការកិច្ចការបំពុលបរិស្ថាននៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម
- កំណត់នីតិវិធីសម្រាប់អនុវត្តនៅក្នុងដំណើរការនៃការត្រួតពិនិត្យ និងការធ្វើអធិការកិច្ចការបំពុលបរិស្ថាននៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម
- ជំរុញការចូលរួមពីម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ក្នុងការអនុវត្តច្បាប់និងវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលបរិស្ថានពីសកម្មភាពរបស់ខ្លួន។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តលើទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដែលអាចបង្កឱ្យមានបញ្ហាបំពុលបរិស្ថានក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

វាក្យស័ព្ទនៃពាក្យដែលប្រើក្នុងប្រកាសនេះ មានសេចក្ដីពន្យល់អត្ថន័យ ដូចខាងក្រោម៖

ក- **ការត្រួតពិនិត្យ:** សំដៅដល់សកម្មភាពចុះជាប្រចាំរបស់មន្ត្រីអធិការកិច្ច នៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដើម្បីផ្ទៀងផ្ទាត់កិច្ចប្រតិបត្តិលក្ខខណ្ឌដែលក្រសួងតម្រូវ អនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងលិខិតអនុញ្ញាតពាក់ព័ន្ធ។

ខ- **ការធ្វើអធិការកិច្ច:** សំដៅដល់សកម្មភាពចុះរបស់មន្ត្រីអធិការកិច្ច ដើម្បីធ្វើការអង្កេត តាមដានស្រាវជ្រាវ ប្រមូលវត្ថុតាង ពាក់ព័ន្ធនឹងករណីបណ្ដឹងឬសេចក្ដីរាយការណ៍ពីបញ្ហាបំពុលបរិស្ថាន ករណីត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តបញ្ជាកែប្រែបញ្ហាបំពុលបរិស្ថាន និងករណីមានការសង្ស័យលួចប្រព្រឹត្តបទល្មើសបង្កការបំពុលបរិស្ថាន។

**គ- មន្ត្រីអធិការ:** សំដៅដល់មន្ត្រីក្រសួងបរិស្ថាន ដែលទទួលភារកិច្ចចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចការបំពុលបរិស្ថាននៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។

**ឃ- សំណល់:** សំដៅដល់សំណល់គ្រប់ប្រភេទក្នុងទម្រង់រឹង រាវ ឬឧស្ម័ន។

**ង- បរិក្ខារប្រព្រឹត្តកម្មសំណល់:** សំដៅដល់សម្ភារៈ ឧបករណ៍ ម៉ាស៊ីន ឬគ្រឿងចក្រ សម្រាប់ស្តុក ស្ទាក់ចាប់ ដកយក ឬសម្អាតជាតិពុលចេញពីសំណល់មុនការបញ្ចេញចោលទៅក្នុងបរិស្ថាន។

## ជំពូកទី២
## សមត្ថកិច្ច

**ប្រការ៥.-**

អគ្គនាយកដ្ឋានគាំពារបរិស្ថាន និងមន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវទទួលខុសត្រូវអនុវត្តការចុះត្រួតពិនិត្យ និងការធ្វើអធិការកិច្ចការបំពុលបរិស្ថាននៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងអនុលោមតាមនីតិវិធីដែលមានចែងនៅក្នុងប្រកាសនេះ។

**ប្រការ៦.-**

ការចុះធ្វើការត្រួតពិនិត្យ និងធ្វើអធិការកិច្ចការបំពុលបរិស្ថាននៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ត្រូវអនុវត្តដោយមន្ត្រីនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន និងមន្ត្រីនៃមន្ទីរបរិស្ថានរាជធានីខេត្ត ដែលទទួលបានការតែងតាំងពីរដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាមន្ត្រីអធិការកិច្ច។

## ជំពូកទី៣
## នីតិវិធីនៃការត្រួតពិនិត្យ និងការធ្វើអធិការកិច្ចការបំពុលបរិស្ថាន

**ប្រការ៧.-**

ការចុះត្រួតពិនិត្យនៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ត្រូវអនុវត្តជាលក្ខណៈប្រចាំយ៉ាងតិច ២ ដងក្នុង១ ឆ្នាំ។

ក្នុងករណីដែល ស្ថានភាពគុណភាពបរិស្ថានជុំវិញទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម មានលក្ខណៈងាយទទួលរងហានិភ័យបំពុលខ្ពស់ ឬការអនុវត្តវិធានការទប់ស្កាត់ការបំពុលរបស់ម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្មនៅមានកម្រិត ការចុះត្រួតពិនិត្យនៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្មទាំងនោះ ដូចដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ ខាងលើ ត្រូវអនុវត្តឱ្យកាន់តែញឹកញាប់។

**ប្រការ៨.-**

ការចុះអនុវត្តការត្រួតពិនិត្យនៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដូចដែលមានចែងនៅក្នុងប្រកាសនេះ ត្រូវមានការជូនដំណឹងជាមុនទៅម្ចាស់ ឬតំណាងស្របច្បាប់របស់ម្ចាស់ទីតាំង។

នីតិវិធីក្នុងការជូនដំណឹង ដូចដែលមានចែងក្នុងវាក្យខ័ណ្ឌទី១ ខាងលើ មិនត្រូវបានអនុវត្តចំពោះការចុះត្រួតពិនិត្យទីតាំងឬតំបន់ ដែលមានការពាក់ព័ន្ធនឹងការបញ្ចេញសំណល់រាវផលិតកម្ម ដោយគ្រាន់តែអនុវត្តតាមបែបបទ និងនីតិវិធីស្របតាមបញ្ញត្តិនៃប្រការ១០ នៃប្រកាសនេះ។

ការចុះអនុវត្តការត្រួតពិនិត្យ ដូចដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ និងវាក្យខ័ណ្ឌទី២ ខាងលើ ត្រូវធ្វើនៅក្នុងពេលម៉ោងការងាររដ្ឋ។

**ប្រការ៩.-**

ការចុះធ្វើអធិការកិច្ចការបំពុលបរិស្ថាន ពាក់ព័ន្ធនឹងករណីបណ្តឹង ឬសេចក្តីរាយការណ៍ពីបញ្ហាបំពុលបរិស្ថាន ករណីត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តបញ្ហាកែប្រែបញ្ហាបំពុលបរិស្ថាន និងករណីមានការសង្ស័យលួចប្រព្រឹត្តបទល្មើសបង្កការបំពុលបរិស្ថាន ពុំតម្រូវឱ្យមានការជូនដំណឹងជាមុនទេ ដោយមន្ត្រីអធិការកិច្ចត្រូវអនុវត្តតាមបែបបទ និងនីតិវិធីស្របតាមបញ្ញត្តិនៃប្រការ១០ នៃប្រកាសនេះ។

ការចុះធ្វើអធិការកិច្ចការបំពុលបរិស្ថាន ដូចដែលមានចែងក្នុងវាក្យខ័ណ្ឌទី១ ខាងលើ អាចធ្វើបាននៅគ្រប់ពេលម៉ោងដែលជាការចាំបាច់ឆ្លើយតបទៅនឹងករណី ឬសកម្មភាពបង្កបញ្ហាបំពុលបរិស្ថាន ដោយមន្ត្រីអធិការកិច្ចត្រូវអនុវត្តតាមបែបបទ និងនីតិវិធីស្របតាមបញ្ញត្តិនៃប្រការ១០ នៃប្រកាសនេះ។

**ប្រការ១០.-**

ការចូលទៅបំពេញភារកិច្ចត្រួតពិនិត្យ ឬធ្វើអធិការកិច្ចការបំពុលបរិស្ថាននៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដូចដែលមានចែងនៅក្នុងប្រកាសនេះ មន្ត្រីអធិការកិច្ចត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោម៖

ក. ប្រើប្រាស់ឯកសណ្ឋានផ្លូវការដែលកំណត់ដោយក្រសួង លើកលែងតែករណីពិសេសតម្រូវឱ្យមានការប្រើសំលៀកបំពាក់ការពារសុវត្ថិភាព

ខ. មានលិខិតបញ្ជាបេសកកម្ម

គ. បង្ហាញអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ

ឃ. ពាក់ប័ណ្ណសំគាល់មន្ត្រីអធិការកិច្ច។

**ប្រការ១១.-**

មន្ត្រីអធិការកិច្ច ដែលទទួលការចាត់តាំងបំពេញភារកិច្ចចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចការបំពុលបរិស្ថាននៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដូចដែលមានចែងនៅក្នុងប្រកាសនេះ មានសិទ្ធិ និងអំណាច ដូចខាងក្រោម៖

ក. បង្គាប់ឱ្យម្ចាស់ ឬតំណាងស្របច្បាប់របស់ម្ចាស់ទីតាំងផ្តល់ព័ត៌មានផ្ទាល់មាត់ ផ្តល់ឯកសារ ឬកំណត់ត្រានានា ទាក់ទងនឹងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម វិធានការគ្រប់គ្រង និងប្រព្រឹត្តកម្មសំណល់ ឬមូលហេតុបង្កឱ្យកើតមានបញ្ហាបំពុលបរិស្ថាន សម្រាប់អនុវត្តតួនាទីដែលកំណត់នៅក្នុងប្រកាសនេះ

ខ. បង្គាប់ឱ្យម្ចាស់ ឬតំណាងស្របច្បាប់របស់ម្ចាស់ទីតាំងបង្ហាញ ឬជូនទៅពិនិត្យទីកន្លែង គ្រឿងបរិក្ខារ ឬសម្ភារៈជាគោលដៅនៃការត្រួតពិនិត្យ និងការធ្វើអធិការកិច្ចការបំពុលបរិស្ថាន

គ. ធ្វើការចែកវត្ថុធាតុដើម គ្រឿងបរិក្ខារគ្រប់គ្រងឬប្រព្រឹត្តកម្មសំណល់ និងប្រព័ន្ធបញ្ចេញសំណល់

ឃ. ធ្វើការប្រមូល ដកយកសំណាក ឬឃាត់ទុកវត្ថុតាងនានាសម្រាប់បម្រើដល់ការងារត្រួតពិនិត្យ ឬធ្វើអធិការកិច្ចការបំពុល

ង. ធ្វើការថតរូបភាពតាមតម្រូវការបច្ចេកទេស ដោយពុំចាំបាច់សុំការឯកភាពពីម្ចាស់ ឬតំណាងស្របច្បាប់របស់ម្ចាស់ទីតាំង

ច. បង្គាប់ឱ្យម្ចាស់ ឬតំណាងស្របច្បាប់របស់ម្ចាស់ទីតាំង ធ្វើការផ្អាកសកម្មភាពឬដំណើរការផ្នែកណាមួយជាបណ្ដោះអាសន្ន ក្នុងករណីដែលមានការរកឃើញថាមានការពាក់ព័ន្ធ ឬបង្កការបំពុលបរិស្ថានជាក់ស្ដែង។

**ប្រការ១២.-**

ក្នុងពេលចុះបំពេញការងារត្រួតពិនិត្យ ឬធ្វើអធិការកិច្ចការបំពុល ដូចដែលមានចែងនៅក្នុងប្រកាសនេះ មន្ត្រីអធិការកិច្ចត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោម៖

ក.ធ្វើការប្រជុំជាមួយម្ចាស់ ឬតំណាងស្របច្បាប់របស់ម្ចាស់ទីតាំង ដើម្បីបង្ហាញពីសមាសភាពមន្ត្រីចូលរួម ពីគោលបំណងនិងសកម្មភាពការងារដែលត្រូវអនុវត្ត និងពីការប្រមូលព័ត៌មានដែលពាក់ព័ន្ធនឹងទីតាំង ឬបញ្ហាបំពុលបរិស្ថានដែលកើតមាន

ខ. ធ្វើការកត់ត្រាឱ្យបានលម្អិត និងច្បាស់លាស់នូវព័ត៌មានដែលផ្ដល់ដោយម្ចាស់ ឬតំណាងស្របច្បាប់របស់ម្ចាស់ទីតាំង និងដែលបានពិនិត្យឃើញនៅតាមទីកន្លែង ឬគោលដៅត្រួតពិនិត្យ ឬធ្វើអធិការកិច្ចការបំពុលបរិស្ថាន

គ. បំពេញកំណត់ហេតុយកសំណាក ចាប់យកឬឃាត់ទុកវត្ថុតាង និងថតរូបភាព ស្របតាមបែបបទនិងនីតិវិធី ដែលកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ឃ. ធ្វើការប្រជុំបូកសរុបលទ្ធផលត្រួតពិនិត្យ ឬធ្វើអធិការកិច្ចការបំពុលបរិស្ថានជាមួយម្ចាស់ ឬតំណាងស្របច្បាប់របស់ម្ចាស់ទីតាំង ដោយត្រូវធ្វើកំណត់ហេតុបញ្ជាក់ពីបញ្ហាដែលបានពិនិត្យឃើញ ឬសេចក្ដីបង្គាប់ឱ្យមានការកែប្រែជាបន្ទាន់

ង. ផ្ទៀងផ្ទាត់ខ្លឹមសារកំណត់ហេតុ ដោយមានការដឹងឮពីម្ចាស់ ឬតំណាងស្របច្បាប់នៃទីតាំងតាមរយៈការអាន ការបកប្រែ ការផ្ដិតស្នាមមេដៃលើកំណត់ហេតុ និងការផ្ដល់ច្បាប់ចម្លងទៅគ្រប់តំណាងចូលរួម។

ច. នាំយកសំណាកសំណល់មកវិភាគនៅមន្ទីរពិសោធន៍ក្រសួងបរិស្ថាន។

**ប្រការ១៣.-**

ក្នុងករណីពេលចុះអនុវត្តការត្រួតពិនិត្យ ឬធ្វើអធិការកិច្ចការបំពុលបរិស្ថាន រកឃើញបទល្មើសជាក់ស្ដែងបង្កឱ្យមានការបំពុលបរិស្ថាន មន្ត្រីអធិការកិច្ច ដោយបន្ថែមទៅលើនីតិវិធីដូចដែលមានចែងនៅក្នុងប្រការ១២ នៃប្រកាសនេះ ត្រូវអនុវត្តនីតិវិធី ដូចខាងក្រោម៖

ក. ប្រមូលវត្ថុតាង ឬសំណាកពាក់ព័ន្ធនឹងបទល្មើស និងធ្វើកំណត់ហេតុដោយឡែកអំពីបទល្មើសជាក់ស្ដែងដែលបានរកឃើញ ដោយត្រូវអនុលោមតាមគំរូសំណុំលិខិតដោះស្រាយបទល្មើសបំពុលបរិស្ថាន

ខ. ចាត់វិធានការផ្អាកជាបណ្ដោះអាសន្ននូវសកម្មភាពដែលបង្ក ឬនាំឱ្យកើតមានបទល្មើសបំពុលបរិស្ថាន ប្រសិនបើករណីបទល្មើសបង្កការបំពុលធ្ងន់ធ្ងរដល់បរិស្ថាន ឬសុខភាពមនុស្ស សត្វ

និងត្រូវជូនដំណឹងជាបន្ទាន់មកក្រសួង។ ក្នុងករណីចាំបាច់ មន្ត្រីអធិការកិច្ចអាចស្នើសុំមកក្រសួង ឬស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីសុំមតិណែនាំឬកិច្ចអន្តរាគមន៍។

**ប្រការ១៤.-**

មន្ត្រីអធិការកិច្ច ដោយអនុលោមតាមសិទ្ធិនិងអំណាចដូចដែលមានចែងក្នុងប្រការ១១ នៃប្រកាសនេះ ត្រូវមានការទទួលខុសត្រូវក្នុងការរក្សាការសម្ងាត់នៃព័ត៌មាន ឯកសារ កំណត់ត្រា រូបភាព និងលទ្ធផលវិភាគសំណាក ដែលប្រមូលបានក្នុងពេលធ្វើការត្រួតពិនិត្យ ឬធ្វើអធិការកិច្ចការបំពុលបរិស្ថាន លើកលែងតែមានការអនុញ្ញាតដោយច្បាប់ ឬការបង្គាប់របស់តុលាការ។

**ប្រការ១៥.-**

ម្ចាស់ ឬតំណាងស្របច្បាប់របស់ម្ចាស់ទីតាំង ត្រូវផ្តល់កិច្ចសហការជាមួយមន្ត្រីអធិការកិច្ច ដើម្បីបំពេញភារកិច្ចត្រួតពិនិត្យ ឬធ្វើអធិការកិច្ចការបំពុលបរិស្ថាន ដូចដែលមានចែងនៅក្នុងប្រកាសនេះ។

ក្នុងករណី មានការរារាំងការចូលក្នុងទីតាំង រាំងឬរំខានការបំពេញភារកិច្ចរបស់មន្ត្រីអធិការកិច្ច ឬពុំអនុវត្តតាមការបង្គាប់ ឬការតម្រូវរបស់មន្ត្រីអធិការកិច្ច ដូចដែលមានចែងនៅក្នុងប្រកាសនេះ ម្ចាស់ ឬតំណាងស្របច្បាប់របស់ម្ចាស់ទីតាំង ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ១៦.-**

ក្រោយការចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចការបំពុល មន្ត្រីអធិការកិច្ច ត្រូវរៀបចំនិងដាក់ជូនថ្នាក់ដឹកនាំក្រសួង ឬមន្ទីរ ពិនិត្យរបាយការណ៍លទ្ធផលនៃការចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចការបំពុលបរិស្ថានក្នុងរយៈពេលមិនលើសពី១០ថ្ងៃ (ថ្ងៃបំពេញការងារ) គិតចាប់ពីថ្ងៃចុះបំពេញការងារ។

ក្រោយការពិនិត្យ និងសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង ឬមន្ទីរ មន្ត្រីអធិការកិច្ច ត្រូវបន្តការអនុវត្តវិធានការជាបន្ទាន់ទៅតាមអនុសាសន៍ណែនាំ ឬសេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង ឬមន្ទីរ។

**ប្រការ ១៧.-**

អគ្គនាយកដ្ឋានគាំពារបរិស្ថាន ត្រូវចុះពង្រឹងសមត្ថភាព ពិនិត្យនិងវាយតម្លៃការអនុវត្តការកិច្ចត្រួតពិនិត្យ និងធ្វើអធិការកិច្ចរបស់មន្ទីរបរិស្ថានរាជធានី ខេត្ត ដែលបានប្រគល់ឱ្យអនុវត្តនៅក្រោមប្រកាសនេះ ដើម្បីសរុបរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង។

## ជំពូកទី៤
## ទណ្ឌកម្ម

**ប្រការ១៨.-**

មន្ត្រីអធិការកិច្ច ដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលដូចដែលមានក្នុងអនុក្រឹត្យស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងច្បាប់ជាធរមាន។

**ប្រការ១៩..**

ម្ចាស់ ឬតំណាងស្របច្បាប់របស់ទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដែលរារាំងការចូលក្នុងទីតាំង ឬពុំព្រមផ្តល់កិច្ចសហការសម្រាប់ការបំពេញភារកិច្ចរបស់មន្ត្រីអធិការកិច្ច ដូចមានចែងកំណត់នៅក្នុងប្រកាសនេះ ត្រូវទទួលទណ្ឌកម្ម ឬទោសអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ២០..**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋានចំណុះក្រសួង អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យរដ្ឋមន្ត្រី ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

ព្រះរាជាណាចក្រកម្ពុជា ក្រសួងបរិស្ថាន

**សាយ សំអាល់**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងរ៉ែ និងថាមពល
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងយុត្តិធម៌
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- តុលាការកំពូល
- សាលាឧទ្ធរណ៍
- សាលាដំបូងរាជធានី ខេត្ត
- ដូចប្រការ២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ